From
the People of Japan

# ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស | តក្កដា | ២០២១

# គម្រោង
# ការកសាងសមត្ថភាពសម្រាប់ការចូលរួមរបស់ពលរដ្ឋ ការកសាងសន្តិភាព និងកិច្ចសន្ទនាប្រកបដោយបរិយាបន្នៈ ឆ្ពោះទៅរកអភិបាលកិច្ចប្រកបដោយបរិយាបន្ន និងការចូលរួម

## ១. អ្វីទៅជា ការសិក្សាអំពីនវានុវត្តន៍សំរាប់រដ្ឋបាលមូលដ្ឋាន ?

ភាពស្មុគស្មាញនៃការអភិវឌ្ឍ ត្រូវការវិធីសាស្ត្រដែលមានភាពបត់បែន និងនវានុវត្តន៍ក្នុងការបង្កើតនូវដំណោះស្រាយ និងដោះស្រាយបញ្ហាសម្រាប់ពលរដ្ឋប្រកបដោយបរិយាបន្ន។ UNDP បាន និងកំពុងផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជំរុញការបង្កើតថ្មី និងនវានុវត្តន៍សម្រាប់មន្ត្រីថ្នាក់ក្រោមជាតិជំនាន់ក្រោយ តាមរយៈគំនិតផ្តួចផ្តើមស្តីពីការសិក្សារៀនសូត្រអំពីនវានុវត្តន៍ ក្នុងភាពជាដៃគូជាមួយ សាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) ក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ។ ការសិក្សារៀនសូត្រអំពីនវានុវត្តន៍សម្រាប់រដ្ឋបាលមូលដ្ឋាននេះត្រូវបានបង្កើតឡើងដោយផ្អែកលើសៀវភៅកម្រងអំពីនវានុវត្តន៍របស់ នេសតា (Nesta) និងបទពិសោធន៍ល្អៗដែលទទួលបានពីវគ្គបណ្តុះបណ្តាលសាកល្បងជាមួយមន្ត្រីរាជការមកពីវិស័យសុខភាពសាធារណៈ និងវិស័យអប់រំក្នុងឆ្នាំ ២០២០ តាមរយៈកិច្ចសហការជាមួយសាលាភូមិន្ទរដ្ឋបាល (RSA) និងក្រសួងមុខងារសាធារណៈ (MOCS)។ វិធីសាស្ត្រនៃការសិក្សាដាក់បញ្ចូលគ្នារវាងដំណោះស្រាយផ្អែកលើបញ្ហាជាក់ស្តែង និងទ្រឹស្តីជាមួយនិងនវានុវត្តន៍ និងការបង្កើតថ្មី ក្នុងគោលដៅពង្រឹងទំនាក់ទំនងការងារ និងកិច្ចសហការរវាងមន្ត្រីរាជការ និងអង្គការសង្គមស៊ីវិល(CSOs) ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍន៍នានា។ រចនាសម្ព័ន្ធនៃការបណ្តុះបណ្តាល ផ្អែកលើសសរស្តម្ភចំនួនបី គឺការធ្វើការជាមួយគ្នា ជម្រុញការផ្លាស់ប្តូរ និងការពន្លឿនការសិក្សារៀនសូត្រ។ សសរស្តម្ភទាំងនេះជាមូលដ្ឋានសម្រាប់ការសិក្សារៀនសូត្រអំពីនវានុវត្តន៍ក្នុងការអាចបង្កើតឲ្យមានជាមធ្យោបាយថ្មីមួយសម្រាប់មន្ត្រីរាជការថ្នាក់ក្រោមជាតិ ក្នុងការស្វែងរកគំនិតថ្មីៗ តាមរយៈការធ្វើការជាមួយភាគីពាក់ព័ន្ធ ការតស៊ូមតិតាមបែប storytelling ដើម្បីការផ្លាស់ប្តូរ និងការស្វែងយល់ពីការគិតជាប្រព័ន្ធដើម្បីពង្រឹងយន្តការនៃការចូលរួមរបស់ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធ។

**Introduction**
Innovation for Local Administration



**Module 1**
Citizen and Stakeholder Engagement



**Module 2**
Data Literacy and Evidence



**Module 3**
Systems Thinking



**Module 4**
Problem Solving



**Module 5**
Storytelling and Advocacy



**Module 6**
Enabling Creative Environment



## លទ្ធផលនៃការបណ្តុះបណ្តាលគ្រូបង្គោល៖

សំណួរ៖ តើអ្នកឃើញពីភាពចាំបាច់នៃការសិក្សារៀនសូត្រអំពីនវានុវត្តន៍ សម្រាប់មន្ត្រីរដ្ឋបាលមូលដ្ឋានដែរឬទេ ?

ការឆ្លើយតប




សំណួរ៖ តើមេរៀនណាខ្លះដែលមានសារសំខាន់ជាងគេសំរាប់មន្ត្រីរដ្ឋបាលមូលដ្ឋាន ?(ជ្រើសរើសអ្វីដែលត្រូវ)

ការឆ្លើយតប




## ២. តើអ្នកណាជា «អ្នកប្រើប្រាស់» នូវការសិក្សារៀនសូត្រអំពីនវានុវត្តន៍នេះ ?

«ការរៀបចំដំណើរការកែសម្រួលច្បាប់ដែលពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល» គឺជាផ្នែកមួយនៃកិច្ចការគម្រោង ដែលជាចំណែកមួយនៃនវានុវត្តន៍ សម្រាប់ការបណ្តុះបណ្តាលរដ្ឋបាលមូលដ្ឋាន ដែលត្រូវបានរៀបចំ និងបង្រៀនដោយ NASLA។ «ការលើកកម្ពស់ការចូលរួមពីអង្គការសង្គមស៊ីវិលក្នុងដំណើរការធ្វើវិសោធនកម្មច្បាប់» តាមរយៈការប្រមូលមតិយោបល់របស់អង្គការសង្គមស៊ីវិលគ្រប់វិស័យទាំងអស់ និងការស្វែងយល់ពីតម្រូវការរបស់អង្គការសង្គមស៊ីវិលតាមរយៈមាត្រាជាក់លាក់នានា គឺជាដំណោះ ស្រាយមួយក្នុងចំណោមដំណោះស្រាយមួយចំនួន ដែលលើកឡើងដោយសិក្ខាកាម។ បន្ទាប់ពីវគ្គបណ្តុះបណ្តាល UNDP បានសួរសិក្ខាកាមថា តើអ្នកណាជា «អ្នកប្រើប្រាស់» ចម្បង ដែលជួបនូវបញ្ហាប្រឈម និងត្រូវការដំណោះស្រាយ។ សិក្ខាកាមបានឆ្លើយថា «អង្គការសង្គមស៊ីវិលជាអ្នកប្រើប្រាស់ចម្បង» និង «យើងខិតខំធានាឲ្យមានការចូលរួមពីអ្នកប្រើប្រាស់ ដោយការសហការជាមួយមន្ទីរ និងក្រសួងដែលពាក់ព័ន្ធដើម្បីពិភាក្សាអំពីចន្លោះប្រហោង និងបញ្ហាប្រឈមដែលអង្គការសង្គមស៊ីវិលកំពុងជួបប្រទះ»។

ចំនុចស្នូលនៃការសិក្សារៀនអំពីនវានុវត្តន៍សម្រាប់រដ្ឋបាលមូលដ្ឋាន គឺ វិធីសាស្ត្រដែលផ្តោតលើមនុស្ស និងអ្នកប្រើប្រាស់ ដែលឈានដល់ដំណោះស្រាយដែលផ្តល់សិទ្ធិដល់អ្នកប្រើប្រាស់ និងឲ្យពួកគេចូលរួមក្នុងការសម្រេចចិត្ត។ ការអនុវត្តនូវវិធីសាស្តថ្មីនេះ ទាមទារនូវកិច្ចខិតខំប្រឹងប្រែងរួមគ្នា។ UNDP នឹងបន្តលើកកម្ពស់គំនិតផ្តួចផ្តើមថ្មីៗនៅតាមមូលដ្ឋាន ដូចជាដំណោះស្រាយដែលបានស្នើនៅក្នុងកិច្ចការខាងលើ ដែលនឹងផ្តល់នូវអត្ថប្រយោជន៍ដ៏មានអត្ថន័យនាពេលអនាគត។

«ពួកយើងចង់សិក្សាលំអិតអំពីបញ្ហាប្រឈមរបស់ពួកគេ(CSO) ជាពិសេសគឺការទំនាក់ទំនងជាមួយក្រសួង។ យើងក៏ចាប់អារម្មណ៍ ចង់ដឹងថាមធ្យោបាយទំនាក់ទំនងមួយណាដែលសមស្របជាងគេ»

## ៣. ការបំផុសគំនិតដោយប្រើប្រាស់វិធីសាស្ត្រមានស្រាប់

តាមរយៈការស្វែងយល់អំពីកម្មវិធីអភិវឌ្ឍន៍នានា និងការគាំទ្រទៅលើកិច្ចការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចពិភាក្សានៅថ្នាក់ក្រោមជាតិនៅកម្ពុជា ព្រមទាំងសារសំខាន់នៃចំណេះដឹងដែលមានបច្ចុប្បន្នភាព ក្នុងបរិបទមូលដ្ឋាន UNDP បានប្រើប្រាស់វិធីសាស្ត្រសិក្សាបែប ការផ្លាស់ប្តូរបែបវិជ្ជមាន (Positive Deviance) ដើម្បីសិក្សាអំពីតួអង្គនៅថ្នាក់មូលដ្ឋានដែលមានស្រាប់ អំពីការរៀបចំ និងការអភិវឌ្ឍនូវសកម្មភាពគម្រោងសម្រាប់ការកសាងសមត្ថភាព។ ការផ្លាស់ប្តូរតាមបែបវិជ្ជមាន គឺជាវិធីសាស្ត្រនវានុវត្តន៍មួយ ដែល UNDP បានប្រើប្រាស់ក្នុងការស្វែងយល់អំពី ការកំណត់នូវដំណោះស្រាយមូលដ្ឋានដែលមានភាពអវិជ្ជមាន នៅក្នុងសហគមន៍ និងការធ្វើការអភិវឌ្ឍ (១)។ ដូចករណីខាងលើនេះ ការផ្លាស់ប្តូរបែបវិជ្ជមាន បានបង្ហាញអំពី ដំណោះស្រាយចំពោះបញ្ហាដែលមនុស្សកំពុងប្រឈមតាមរយៈការសង្កេត មើលទៅលើ បុគ្គលឬក្រុមមនុស្សដែលប្រកាន់យក «អាកប្បកិរិយាឬវិធីសាស្ត្រមិនធម្មតា» ប៉ុន្តែទទួលបានលទ្ធផលប្រសើរជាង បើប្រៀបធៀបទៅនឹងការប្រើប្រាស់អាកប្បកិរិយា ឬវិធីសាស្ត្រធម្មតានៃបុគ្គល និងក្រុមសហគមន៍ដទៃដែលមានធនធានដូចគ្នា។

កម្មវិធីពន្លឿនការអភិវឌ្ឍ (Accelerator Labs) នៃ UNDP ប្រចាំកម្ពុជា បានប្រើប្រាស់ការសម្ភាសន៍តាមអនឡាញទៅលើ អង្គការសង្គមស៊ីវិលចំនួន ១៥ នៅតាមបណ្តាខេត្ត និងកម្រិតសហគមន៍។ UNDP បានស្វែងយល់អំពីវិធីសាស្ត្រ «មិនទូទៅប៉ុន្តែផ្តល់ភាពជោគជ័យ» តាមរយៈបទពិសោធន៍របស់អង្គការសង្គមស៊ីវិលក្នុងកិច្ចការងារ ជំរុញរបៀបវារៈរបស់ខ្លួននៅតាមមូលដ្ឋានជាមួយនឹងលទ្ធផលផ្លែផ្កា។ វិធីសាស្ត្របែបនេះ រួមមានការផ្តល់អាទិភាពក្នុងតួនាទីសម្របសម្រួលជាមួយដៃគូ និងអាជ្ញាធរមូលដ្ឋាន កំណត់រចនាសម្ព័ន្ធកម្មវិធី/បច្ចេកទេស និងបន្តឲ្យមានការចូលរួមរបស់អាជ្ញាធរមូលដ្ឋានក្នុងការត្រួតពិនិត្យបង្កើនការយល់ដឹង និងការកសាងសមត្ថភាព។ UNDP នឹងបញ្ចូលការអនុវត្តទាំងនេះក្នុងគម្រោង ដើម្បីរៀបចំកម្មវិធីកសាងសមត្ថភាពនាពេលអនាគត រួមទាំងកិច្ចការសន្ទនាភាពជាដៃគូថ្នាក់ខេត្ត មានខេត្តកំពង់ចាម កំពត រតនគិរី និងសៀមរាប។